## **បទសក្ខីកម្មក្លែងក្លាយ (ធាតុផ្សំបទល្មើស)**

-យល់ឃើញថា ការដែលសាលាដំបូងរាជធានីភ្នំពេញ ក៏ដូចជាសាលាឧទ្ធរណ៍ផងដែរ ដែលសម្រេចផ្តន្ទាទោសឈ្មោះ...**យិន** ពីបទៈសក្ខីភាពក្លែងក្លាយនោះ គឺជាការភ័ន្តច្រឡំ ពីព្រោះថា**មាត្រា៥២** នៃច្បាប់ព្រហ្មទណ្ឌអន្តរកាលដែលចែងអំពីបទល្មើសសក្ខីភាពក្លែងក្លាយ គឺសំដៅអនុវត្តទៅលើប្រធាននៃបទល្មើសគឺជាសាក្សីនិងអ្នកជំនាញដែលបានបង្ហាញភស្តុតាងឬហេតុផលណា ដែលមិនពិតដល់តុលាការ ប៉ុន្តែករណីនេះចំពោះជនជាប់ចោទឈ្មោះ...**យិន** វិញគឺជាភាគីនៅក្នុងរឿងក្តី។ ហេតុដូច្នេះ បញ្ញត្តិច្បាប់ខាងលើ មិនអាចយកមកអនុវត្តធ្វើការចោទប្រកាន់លើឈ្មោះ...**យិន** បានទេ។ ដូចនេះតាមមាត្រា៤៤០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ តុលាការកំពូលសម្រេចឲ្យជនជាប់ចោទឈ្មោះ...**យិន** រួចផុតពីបទល្មើសក្លែងសក្ខីភាពក្លែងក្លាយ។ រីឯតុលាការអង្គសេចក្តីសម្រេចផ្តន្ទាទោសឈ្មោះ...**យិន** ពីបទក្លែងលិខិតឯកជននោះជាការត្រឹមត្រូវហើយ ប៉ុន្តែដោយនាពេលបច្ចុប្បន្ន ក្រមព្រហ្មទណ្ឌមានអានុភាពអនុវត្ត ហើយតាមបញ្ញត្តិមាត្រា៦២៧នៃក្រមថ្មីនេះ ចែងអំពីទោសចំពោះបទល្មើសក្លែងបន្លំឯកសារមានលក្ខណៈស្រាលជាងទោស ដែលមានចែងក្នុងបញ្ញត្តិមាត្រា៥០នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ដែលជាច្បាប់ចាស់នោះ។ ដូច្នេះ តាមស្មារតីនៃមាត្រា១០នៃក្រមព្រហ្មទណ្ឌ តុលាការគប្បីយកបទបញ្ញត្តិនៃច្បាប់ថ្មី ដែលចែងអំពីទោសស្រាលជាងមកអនុវត្ត ដើម្បីជាផលប្រយោជន៍របស់ជនជាប់ចោទ (សាលដីកាតុលាការកំពូលលេខ ២៨៦ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៣, ទំ.៣)។

**មាត្រា៥៤៥ បទផ្តល់សក្ខីកម្មក្លែងក្លាយនិងការលើកលែង** (ក្រមព្រហ្មទណ្ឌឆ្នាំ២០១០)

*សក្ខីកម្មកុតកុហកដែលធ្វើក្រោយពីបានស្បថនៅមុខតុលាការឬនៅមុខមន្ត្រីនគរបាលយុត្តិធម៌ ដែលធ្វើសកម្មភាពនៅក្នុងក្របខ័ណ្ឌនៃដីកាចាត់ឱ្យសួរចម្លើយ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី២(ពីរ)ឆ្នាំទៅ៥(ប្រាំ)ឆ្នាំ និងពិន័យជាប្រាក់ពី ៤ ០០០ ០០០ (បួនលាន) រៀលទៅ ១០ ០០០ ០០០ (ដប់លាន) រៀល ។ សាក្សីកុតកុហកត្រូវបានលើកលែងឱ្យរួចផុតពីទោស ប្រសិនបើសាក្សីនេះប្រែក្រឡាស់ដោយឯកឯងនូវសក្ខីកម្មរបស់ខ្លួន ហើយនិយាយតែការពិតមុនសេចក្តីសម្រេចបញ្ចប់នីតិវិធីស៊ើបសួរឬនីតិវិធីជំនុំជម្រះ ។*

**កំណត់សំគាល់៖ ក.** ជាតុផ្សំនៃបទល្មើស មានសកម្មភាពនិងអត្តនោម័ត។ ប្រភេទមនុស្សដែលប្រព្រឹត្តល្មើសចែងក្នុងបទប្បញ្ញត្តិច្បាប់ ជាប្រធាននៃបទល្មើស (subject of offense)។ សម្រាប់បទសក្ខីកម្មក្លែងក្លាយ ប្រធានបទល្មើសគឺជាសាក្សី។ ការចោទជនល្មើសដែលជាភាគីនៃសំណុំរឿង ជាប្រធាននៃបទល្មើសនេះ វាជាការអនុវត្តច្បាប់ខុស ដែលជាមូលដ្ឋានឲ្យតុលាការកំពូល អាចទទួលពិនិត្យបណ្តឹងសាទុក្ខ ព្រមទាំងសម្រេចឲ្យជនជាប់ចោទរួចផុតពីបទចោទ។ **ខ.** តុលាការកំពូល បានយោងដល់គោលការណ៍នីត្យានុកាល(មាត្រា១០) ទាមទារឲ្យអនុវត្តទោសតាមមាត្រា៥៤៥ ដែលស្រាលជាងមាត្រា៥០នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ដែលដាក់ទោស៥ឆ្នាំក្នុងពន្ធនាគារ។